# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ ២៩៣៤
ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១
ជំនុំជម្រះលេខ ១៩១២
ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១១
សាលក្រមព្រហ្មទណ្ឌ
លេខ ២១ គបឞ "ឆ"
ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០១២

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នាសាលសវនាការ នៃសាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១២ ដោយមានសមាសភាពដូចតទៅ ÷

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

**ចៅក្រមប្រឹក្សា**

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

លោកស្រី [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ២៩៣៤ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១ ដែលមានជនជាប់ចោទ ÷

១-ឈ្មោះ [redacted] តុលា ហៅ តាំង ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ នៅផ្ទះ ទីកន្លែងកំណើតនៅភូមិភ្នំមាស ឃុំតឹងហៀប ស្រុកតាកូវ ខេត្តព្រះត្រពាំង (កម្ពុជាក្រោម) ទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ [redacted] ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន។

ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ៥០០ តព្រ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០១១ ។

២-ឈ្មោះ [redacted] ភក្តី ហៅ សៀច ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ មុខរបរ កម្មកររោងចក្រ ទីកន្លែងកំណើតនៅ ភូមិអង្គពក ឃុំម៉ុនជ័យ ស្រុករំដួល ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ន នៅផ្ទះជួលលេខ [redacted] នៅលីវ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ទោសពីមុនគ្មាន ជាទីតិជន។

ឃាត់ខ្លួននៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០១១



Scanned with CamScanner

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៨១៣ គព្រ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ២០១១ ។

៣-ឈ្មោះ [redacted] សំណាង ហៅ តឹង ភេទប្រុស អាយុ ១៤ឆ្នាំ ជាតិខ្មែរ មុខរបរ សិស្សថ្នាក់ទី៨ ទីកន្លែងកំណើតនៅភូមិភ្នំមាស ឃុំតឹងហៀប ស្រុកតាកូវ ខេត្តព្រះត្រពាំង (កម្ពុជាក្រោម) ទីលំនៅបច្ចុប្បន្ននៅផ្ទះជួល ផ្លូវលំ [redacted] រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ទោសពីមុនគ្មាន ជា អនីតិជន ។

ឃាត់ខ្លួននៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០១១

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៨១៤ គព្រ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ២០១១ ។

មេធាវីការពារសិទ្ធិជនជាប់ចោទទាំងបីលោក [redacted] វុទ្ធា ។

ជាប់ចោទពីបទ ឃាតកម្ម ប្រព្រឹត្តនៅចំណុចសួនច្បារមុខការ៉ាស់សាំងសូគីម៉ិច ផ្លូវជាតិលេខ៥ ក្រុមទី៥ ភូមិឃ្លាំងសាំង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ៥ ឃុំកងតាណឹង ស្រុកកងមាស ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិ៥ ឃុំ [redacted] ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១១ វេលាម៉ោង ២០ និង ០០នាទី មានករណី ឃាតកម្ម កើតឡើងនៅចំណុចសួនច្បារមុខការ៉ាស់សាំងសូគីម៉ិច ផ្លូវជាតិលេខ៥ ក្រុមទី៥ ភូមិឃ្លាំងសាំង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដោយខណៈពេលជនរងគ្រោះឈ្មោះ [redacted] ភារៈ ភេទប្រុស អាយុ ១៩ឆ្នាំ កំពុងអង្គុយលេងនៅចំណុចកើតហេតុខាងលើ ស្រាប់តែជនត្រូវចោទឈ្មោះ [redacted] តុលា ហៅ តាំង គិតថាជនរងគ្រោះមើលមុខខ្លួន ហើយក៏បបួលជនត្រូវចោទឈ្មោះ [redacted] ភក្តី ហៅ សៀច និងឈ្មោះ [redacted] សំណាង ហៅ តឹង ទៅព្រួតវាយលើជនរងគ្រោះឈ្មោះ [redacted] ភារៈ តែម្តងដោយខណៈពេលប្រតាយប្រតប់គ្នានោះ ជនត្រូវចោទបានយកដែកកាំកង់ម៉ូតូចាក់លើជនរងគ្រោះត្រូវពោះមួយកន្លែង និងដើមទ្រូងមួយកន្លែង បណ្តាលឱ្យជនរងគ្រោះស្លាប់នៅនឹងកន្លែងតែម្តង ភ្លាមនោះបក្សពួកជនល្មើសក៏បានគេចខ្លួនអស់ ។

-បានឃើញរបាយការណ៍សំយោគលេខ ១១៤/១១ របក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១១ របស់អធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ១៨៦៩ អយណ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ២០១១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ៣១៧៥ ដជ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ របស់ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ ។

<u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ [redacted] ភក្តី ហៅ សៀច បានឆ្លើយថា កាលពីថ្ងៃកើតហេតុខ្លួនបាននាំសង្សារខ្លួនដើរលេងក្នុងសួន ហើយបានជួបមិត្តភក្តិឈ្មោះ អាតាំង និងអាតឹង នៅពេលនោះខ្លួនឃើញ អាតាំង រោក់គេមួយជើង ឈ្មោះ អាតាំង ជាអ្នកវាយមុនគេលើជនរងគ្រោះដែលកំពុងអង្គុយលើបង់ ខ្លួនគ្រាន់តែបានជនរងគ្រោះចំនួនបីបួនដៃតែប៉ុណ្ណោះ ហើយខ្លួនបានចេញបាត់ទៅហើយ អាតុលា នៅទីនោះដែល ឈ្មោះ អាតឹង ក៏បានធាក់ជនរងគ្រោះដែរ នៅពេលព្រឹកឡើងខ្លួនបានទូរស័ព្ទសួរ អាតុលា ថាវាជាអ្នកយកដែកកាំកង់ចាក់ជនរងគ្រោះ កាលពីថ្ងៃកើតហេតុ វេលាម៉ោងប្រហែល ៧យប់ ខាងខ្លួនមានគ្នាបីនាក់ ហើយខាងជនរងគ្រោះមានគ្នាបីនាក់ដែល នៅពេលខ្លួនវាយជនរងគ្រោះ ខ្លួនមិនឃើញជនរងគ្រោះមានស្លាកស្នាមអ្វីទេ ។ នៅពេលជនរងគ្រោះកំពុងអង្គុយលេងនៅលើបង់ ខ្លួនបានវាយជនរងគ្រោះចំនួនបីដៃ រួបខ្លួនឈ្មោះ អាតុលា និងពួកម៉ាកខ្លួនឈ្មោះ អាតាំង បាននាំគ្នាទៅវាយជនរងគ្រោះ ។

-ជនជាប់ចោទឈ្មោះ [redacted] សំណាង ហៅ តឹង បានឆ្លើយថា ខ្លួនត្រូវជាបងប្អូនជីដូនមួយ [redacted] ភក្តី ខ្លួនបានវាយជនរងគ្រោះដែលកំពុងអង្គុយលើបង់ចំនួនពីរដៃនៅថ្ងៃកើតហេតុ ខ្លួនពុំមានរបស់អ្វីកាន់ជាប់នឹងដៃនោះទេ ខ្លួនមានមុខរបរជាសិស្សសាលារៀន កាលពីថ្ងៃកើតហេតុខ្លួនឃើញពួកម៉ាកខ្លួនកំពុងប្រតាយប្រតប់គ្នា ខ្លួនក៏បានវាយជនរងគ្រោះពីរដៃ បន្ទាប់មកខ្លួន និងអាតុលា បានរត់ចេញ ហើយនៅកន្លែងកើតហេតុ អាតាំង នៅទីនោះ មិនទាន់បានរត់ចេញទេ ខ្លួនមានអាយុ ១៤ឆ្នាំ ។ កាលពីថ្ងៃកើតហេតុខ្លួនបានដើរលេងជាមួយ អាតុលា និងអាតាំង នៅពេលកើតហេតុខ្លួនក៏បានចូលទៅវាយជនរងគ្រោះដែល ខ្លួនមិនបានដឹងថាជនរងគ្រោះស្លាប់នោះទេ ។

-ឪពុករបស់ឈ្មោះ [redacted] សំណាង ហៅ តឹង ឆ្លើយថា ចាច់ សំណាង កើតនៅខែ កក្កដា ឆ្នាំ១៩៩៧ ។

-ក្រឡាបញ្ជីអានកំណត់ហេតុរបស់ដើមបណ្តឹងឈ្មោះ [redacted] នៅដំណាក់កាលស៊ើបសួរថា កាលពីថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១១ មិត្តភក្តិខ្លួនបានទូរស័ព្ទប្រាប់ខ្លួនថា ប្អូនខ្លួនឈ្មោះ [redacted] ភារៈ ត្រូវពួកជើងកាងចាក់សម្លាប់ហើយ ពេលនោះខ្លួន និងម្តាយបានជួលឡានពីស្រុកកំណើតដើម្បីមកដឹកសពនៅចំណុចសួនថ្មីក្នុងខណ្ឌឫស្សីកែវ ពេលខ្លួន និងម្តាយមកពុំឃើញជនល្មើសទេ ឃើញតែសាកសពប្អូនប្រុស ភ្លាមនោះខាងសមត្ថកិច្ចបានហៅខ្លួនទៅធ្វើកំណត់ហេតុ ដើម្បីប្តឹងជនល្មើសដែលបានសម្លាប់ប្អូនខ្លួន ខ្លួនឃើញស្នាមរបួសរបស់ប្អូនខ្លួនត្រូវជនល្មើសចាក់ចំក្រោមដោះខាងឆ្វេង និងមួយកន្លែងទៀតចុងឆ្អឹងជំនីខាងស្តាំ ពេលខ្លួនទៅ

ដាក់ពាក្យបណ្តឹង ខ្លួនឃើញឈ្មោះ [redacted] ត្រូវសមត្ថកិច្ចកំពុងធ្វើការសាកសួរ ពិករណីសម្លាប់ប្អូនរបស់ខ្លួន ហើយខ្លួនពុំស្គាល់ជនល្មើសទេ គឺស្គាល់តាមរយៈឈ្មោះ [redacted] ពួកជនល្មើសពួកវាមានគ្នាបីនាក់ តែត្រូវបានរត់គេចខ្លួនអស់ ។ ក្រោយមកលោកអធិការរងទទួលផែនព្រហ្មទណ្ឌខណ្ឌឬស្សីកែវ បានប្រាប់ឪពុកធំរបស់ខ្លួនថាចាប់ជនល្មើសបានពីរនាក់ហើយ ចំណែកម្នាក់ទៀតរត់គេចខ្លួនបាត់ហើយរកពុំឃើញទេ សាកសពប្អូនរបស់ខ្លួនត្រូវដឹកយកទៅធ្វើបុណ្យនៅភូមិ៥ ឃុំកងតាណឹង ស្រុកគងមាស ខេត្តកំពង់ចាម ប្អូនរបស់ខ្លួនស្លាប់នេះឈ្មោះ [redacted] ភារៈ ភេទប្រុស អាយុ ១៩ឆ្នាំ មុខរបរកម្មកររោងចក្រទឹកកក ទើបមកពីស្រុក មកធ្វើការភ្នំពេញបានរយៈពេលប្រហែល ពីរខែ ប៉ុណ្ណោះ កន្លងមកខ្លួនមិនធ្លាប់ស្គាល់ជនល្មើសទេ ហើយក៏ពុំធ្លាប់ដឹងថាប្អូនខ្លួនធ្លាប់មានទំនាស់ជាមួយពួកវានោះដែរ ។ ខ្លួនសំណូមពរ សុំទាមទារជំងឺចិត្ត និងថ្លៃធ្វើបុណ្យសពប្អូនរបស់ខ្លួនពីជនល្មើសចំនួន ៤០០០ (បួនពាន់)ដុល្លារអាមេរិក និងសុំតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ ខ្លួនសុំតាំងខ្លួនជាដើមបណ្តឹងជំនួសឪពុក និងម្តាយរបស់ខ្លួនព្រោះឪពុកម្តាយនៅឆ្ងាយពិបាកចុះឡើង ។

-ក្រឡាបញ្ជីអានកំណត់ហេតុរបស់សាក្សីឈ្មោះ [redacted] ឆ្លើយនៅដំណាក់កាលស៊ើបសួរថា កាលពីថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១១ វេលាម៉ោងប្រហែល ៧ និង ៣០នាទីយប់ ខ្លួន និងមិត្តភក្តិពីរនាក់ទៀតនាំគ្នាទៅមាត់ទន្លេសួនច្បារជិតការ៉ាសសាំងសូគីម៉ិច អង្គុយលើបង់មើលគេហាត់ប្រាណ ខ្លួនមានគ្នាបីនាក់ គឺខ្លួន ឈ្មោះ [redacted] និងឈ្មោះ [redacted] ភារៈ កំពុងអង្គុយលើបង់ស្រាប់តែមានមនុស្សប្រុសបីនាក់ ជិះកង់មកជិតនោះ ហើយឈ្មោះ [redacted] ភារៈ បានមើលមុខពួកនោះ បន្ទាប់មកខ្លួនដើរចេញទៅអង្គុយបង់មួយទៀត ពេលនោះមានស្រីវៀតណាមម្នាក់មកឈរនិយាយលេងជាមួយឈ្មោះ [redacted] ភារៈ បានបន្តិចក្រោយមកស្រាប់តែមានអាម្នាក់ដែលជិះកង់ក្នុងចំណោមបីនាក់នោះបានដើរមកសួរថា ឯងម៉េចបានមើលមុខអញ [redacted] ភារៈ បានឆ្លើយថាគ្រាន់មើលលេងទេ ពេលនោះម្នាក់ហ្នឹងដើរចេញបន្តិច អាពីរនាក់ទៀតចូលមកវាយលើឈ្មោះ [redacted] ភារៈ ហើយអាម្នាក់ដែលដើរចេញក៏ត្រឡប់មកបវិញមកវាយឈ្មោះ [redacted] ភារៈ ឃើញដូច្នេះខ្លួន និងឈ្មោះ [redacted] នាំគ្នារត់មិនហ៊ានជួយព្រោះពួកវាមានគ្នាបីនាក់មាឌធំៗ ពេលពួកវាវាយ ឈ្មោះ ភារៈ បានដួលទៅនឹងដីចំណែកពួកវានាំគ្នាដើរទៅជើង ។ ពេលខ្លួនរត់បានប្រហែល ២០ម៉ែត្រខ្លួនងាកក្រោយឃើញអាម្នាក់យកមិនដឹងជាដែក ឬឈើមានរាងវែងចាក់ទៅលើ [redacted] ភារៈ មួយស្របកក្រោយមក ខ្លួនក៏ត្រឡប់ទៅមើល [redacted] ភារៈ វិញ ចំណែកឈ្មោះ [redacted] ដើរទៅរោងចក្រទឹកកកហៅគេមកជួយ តែពេលនោះឈ្មោះ [redacted] ភារៈ បានស្លាប់បាត់ទៅហើយ ។ កន្លងមកខ្លួនមិនធ្លាប់ស្គាល់ ឬមានទំនាស់ជាមួយជនទាំងនោះទេ ចំពោះភិនភាគពួកវា អាម្នាក់រាងទាបកំពស់ប្រហែល ១,៥០ម៉ែត្រ សំបុរស សក់ស្គួត ម្នាក់ទៀតរាងខ្ពស់ប្រហែល ១,៧០ ម៉ែត្រ ពាក់អាវពណ៌សដៃខ្លី ស្លៀកខោខូវប៊យពណ៌ខ្មៅជើងវែង សក់ស្គួតវែង សំបុរស ឯអាម្នាក់ទៀតមាន

កំពស់ប្រហែល ១,៦០ម៉ែត្រ សំបុរស្រអែម ស្លៀកខោពណ៌ខ្មៅជើងវែង ពាក់មួកពណ៌ខ្មៅមាន អក្សរអង់គ្លេស ពួកវាទាំងបីនាក់មានអាយុប្រហែលក្រោម ២០ឆ្នាំ និងលើ ២០ឆ្នាំ ។

-ក្រឡាបញ្ជីអានកំណត់ហេតុរបស់សាក្សីឈ្មោះ [redacted] ឆ្លើយនៅដំណាក់កាលស៊ើបសួរ ថា កាលពីថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១១ វេលាម៉ោងប្រហែល ៧ និង ៣០នាទីយប់ ខ្លួន និង មិត្តភក្តិពីរនាក់ទៀតនាំគ្នាទៅហាត់ទន្លេសួនច្បារជិតការ៉ាសសាំងសូគីម៉ិច ពេលទៅដល់ពួកខ្លួន ទៅឈរមើលគេហាត់ប្រាណមួយសន្ទុះ ក៏នាំគ្នាដើរមកអង្គុយលេងលើកៅអីថ្ម ជិតទុយោប្រេង ពេលនោះឃើញនារីវៀតណាមម្នាក់ដើរមកអង្គុយនិយាយលេងជាមួយជនរងគ្រោះ ព្រោះពួកគេស្គាល់គ្នាយូរហើយ ពេលកំពុងអង្គុយនិយាយគ្នានោះ មានជនម្នាក់មិនធ្លាប់ស្គាល់ដើរចូលមករកពួកខ្លួន ពេលចូលមកដល់ជននោះបានសួរទៅជនរងគ្រោះថាហេតុអីបានជាឯងមើលមុខអញ រួចជនរងគ្រោះឆ្លើយថា មើលលេងភ្លាមនោះមានគ្នាវាពីរនាក់ទៀតដើរចូលមក មើលមុខហើយវាយទៅលើជនរងគ្រោះតែម្តង ដោយឃើញពួកវាមាឌធំៗជាងខ្លួន និងឈ្មោះ [redacted] ក៏បានដើរចេញពីកន្លែងកើតហេតុមិនហ៊ានជួយជនរងគ្រោះឡើយ ពេលពួកវាបីនាក់វាយជនរងគ្រោះអស់ចិត្ត ពួកវាក៏នាំគ្នាដើរទៅជើងបាត់ ហើយខ្លួន និងឈ្មោះ [redacted] ដើរត្រឡប់ទៅមើលជនរងគ្រោះវិញ ដោយឃើញជនរងគ្រោះដួលដេកនៅលើឥដ្ឋក្នុងសួន ខ្លួនឃើញជនរងគ្រោះរបួសធ្ងន់ ខ្លួនដើរទៅរោងចក្រទឹកកកហៅគ្នាមកជួយជនរងគ្រោះ ពេលខ្លួនត្រឡប់មកវិញគេថាជនរងគ្រោះស្លាប់បាត់ទៅហើយ ។ ភិនភាគជនល្មើសទាំងបីនាក់នោះ គឺអាម្នាក់ដែលដើរចូលមុនគេ រាងទាបធាត់ សំបុរស ពាក់អាវ ពណ៌ខៀវ ស្លៀកខោជើងវែង មិនចាំពណ៌ សក់ក្បាលខ្លីស្ទូត កំពស់ប្រហែល ១,៥៥ម៉ែត្រ ចំណែកពីរនាក់ទៀត ម្នាក់រាងស្គមខ្ពស់ កំពស់ប្រហែល ១,៧០ សំបុរស ពាក់អាវមិនចាំ ស្លៀកខោមិនចាំ សក់ក្បាលខ្លី ម្នាក់ទៀត រាងទាបកំពស់ប្រហែល ១,៦០ ស្លៀកពាក់មិនចាំ ។

-ក្រឡាបញ្ជីអានកំណត់ហេតុរបស់សាក្សីឈ្មោះ [redacted] ឆ្លើយនៅដំណាក់កាលស៊ើបសួរថា កាលពីថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១១ វេលាម៉ោងប្រហែល ៧ និង ៣០នាទីយប់ ខ្លួន និងមិត្ត ភក្តិពីរនាក់ទៀតនាំគ្នាទៅហាត់ទន្លេសួនច្បារជិតការ៉ាសសាំងសូគីម៉ិច រហូតដល់ម៉ោង ២០នាទីយប់ ក៏បានឃើញជនល្មើសបីនាក់ ព្រួតគ្នាវាយទៅលើជនម្នាក់ទៀតនៅលើសួនច្បារក្នុងចំណោមជនល្មើសបីនាក់នោះខ្លួនស្គាល់ពីរនាក់ ឈ្មោះ [redacted]តុលា ហៅ តាំង និងឈ្មោះ តឹង អ្នកទាំងពីរជាបងប្អូននឹងគ្នា មានទីលំនៅក្នុងបន្ទាយកងកិត្តិយសត្រៃទ័ពឬស្សីកែវ ឯចំណែកជនម្នាក់ទៀតខ្លួនមិនស្គាល់ទេ ពេលដេញវាយជនរងគ្រោះឈ្មោះ [redacted] តុលា និងឈ្មោះ តឹង បានប្រតាយប្រតប់ទាត់ធាក់រហូតជនរងគ្រោះដួលសន្លប់ទៅលើដី ទើបអ្នកទាំងពីរឈប់វាយ ហើយដើរទៅបាត់ ពេលនោះមាននារីពីរនាក់ និងបុរសម្នាក់ ដើរមកមើលជនរងគ្រោះរបៀបអ្នកស្គាល់គ្នា ឃើញដូច្នេះខ្លួនក៏បានដើរទៅមើលដែរ ហើយបានលើកជនរងគ្រោះឲ្យអង្គុយលើ

កៅអីថ្ម ខ្លួនឃើញជនរងគ្រោះមានសភាពស្លេកស្លាំង មានស្នាមផ្ទុះនៅលើដើមទ្រូង ប៉ុន្តែពុំឃើញមានឈាមហូរមកខាងក្រៅទេ បន្ទាប់មកខ្លួនក៏ជិះម៉ូតូមកផ្ទះវិញ ក៏បានជួបឈ្មោះ [redacted] តុលា និងឈ្មោះ តឹង នៅក្នុងបន្ទាយគ្រែទំព ខ្លួនក៏សួរអ្នកទាំងពីរថាតើយកអ្វីទៅចាក់បានជាជនរងគ្រោះមានស្នាមផ្ទុះនៅលើដើមទ្រូង ពេលនោះឈ្មោះ [redacted] តុលា បានប្រាប់ខ្លួនថាអញយកដែកកាំម៉ូតូចាក់លើជនរងគ្រោះ ព្រមទាំងបានលើកដែកកាំម៉ូតូបង្ហាញខ្លួន ហើយខ្លួនមើលឃើញ គឺជាដែកកាំម៉ូតូ ដែលមានចុងស្រួចប្រាកដមែន បន្ទាបមកខ្លួនបានលឺអ្នកជិតខាងនិយាយថាជនរងគ្រោះបានស្លាប់ ខ្លួនក៏ជិះម៉ូតូមកកន្លែងកើតហេតុ ឃើញប្រជាពលរដ្ឋចោមរោមមើលជាច្រើន ទើបខ្លួនដឹងថាជនរងគ្រោះស្លាប់ប្រាកដមែន ។

**តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា**

តំណាងអយ្យកាសុំរក្សាបទចោទប្រកាន់ តាមដីកាសន្និដ្ឋានស្ថាពរទុកនៅដដែល ។

**មេធាវីការពារសិទ្ធិជនជាប់ចោទសន្និដ្ឋានការពារថា**

កូនក្តីរបស់ខ្លួនឈ្មោះ [redacted] សំណាង គឺបានសារភាពថាពិតជាបានវាយទៅលើជនរងគ្រោះមែន តែគឺមិនបានយកដែកកាំម៉ូតូទៅចាក់លើជនរងគ្រោះឡើយ ហើយក៏បានដឹងតាមរយៈ [redacted] ភក្តី ថាឈ្មោះ អាតាំង ជាអ្នកយកដែកកាំម៉ូតូចាក់ទៅលើជនរងគ្រោះ ហើយរយៈពេលនៃការឃុំខ្លួនជនត្រូវចោទមានរយៈពេលតែ បួនខែ ប៉ុណ្ណោះ តែពេលនេះ គឺឃុំជាងប្រាំខែមកហើយ ដូចនេះ ខ្លួនមានសំណូមពរ សូមឱ្យតុលាការមេត្តាដោះស្រាយជូនកូនក្តីខ្លួនតាមវិធានការណ៍អនីតិជន អាយុ ១៤ឆ្នាំ គឺមានសំណូមពរសុំឱ្យឱ្យកូនក្តីខ្លួនបាននៅក្រៅឃុំ ។

**សំដីចុងក្រោយរបស់ជនជាប់ចោទទាំងពីរនាក់**

សុំឱ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួនផង ។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទទាំងពីរនាក់
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងអំណានចម្លើយសាក្សី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទទាំងពីរនាក់
- ក្រោយពីបានពិនិត្យ ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌមកជំនុំជម្រះលើឈ្មោះ [redacted] តុលា ហៅ តាំង ,ឈ្មោះ [redacted] ភក្តី ហៅ សៀច និងឈ្មោះ [redacted] សំណាង ហៅ តឹង ពីបទ ឃាតកម្ម ប្រព្រឹត្តនៅចំណុចសួនច្បារមុខការ៉ាសសាំងសូគីម៉ិច ផ្លូវជាតិលេខ៥ ក្រុមទី៥ ភូមិឃ្លាំងសាំង សង្កាត់ឬស្សីកែវ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១១ បទល្មើសព្រហ្ម/



Scanned with CamScanner

ទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

២-តាមរបាយការណ៍សរុបលេខ ១១៤/១១ របក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ២០១១ របស់អធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ បញ្ជាក់ថា កាលពីថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១១ នៅចំណុចស្ទួនច្បារមាត់ទន្លេ ទល់មុខស្ថានីយ៍ប្រេងឥន្ធនៈឫស្សីកែវ ពិតជាមានបទល្មើស ឃាតកម្ម មួយកើតឡើងដែលប្រព្រឹត្តដោយឈ្មោះ [redacted] តុលា ហៅ តាំង , ឈ្មោះ [redacted] ភក្តី ហៅ សៀច និងឈ្មោះ [redacted] សំណាង ហៅ តឹង ទៅលើជនរងគ្រោះឈ្មោះ [redacted] ភារៈ ពិតប្រាកដមែន ។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ភក្តី ហៅ សៀច បានឆ្លើយសារភាពថា នៅថ្ងៃកើតហេតុឈ្មោះ [redacted] តុលា បានប្រាប់ខ្លួនថា មានគេមើលមុខវា ហើយក៏បបួលខ្លួន និងឈ្មោះ [redacted] សំណាង ហៅ តឹង ទៅវាយជនរងគ្រោះ ពេលដើរទៅដល់ឈ្មោះ [redacted] តុលា ហៅ តាំង បានលោតធាក់ជនរងគ្រោះមួយជើងធ្លាក់ពីលើបង់អង្គុយ ហើយខ្លួន និងឈ្មោះ [redacted] សំណាង ក៏ចូលវាយដែរ ដោយវាយនឹងដៃ ។

៤-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សំណាង ហៅ តឹង បានឆ្លើយសារភាពថា នៅថ្ងៃកើតហេតុខ្លួន និងឈ្មោះ [redacted] តុលា ហៅ តាំង ព្រមទាំងមិត្តភក្តិរបស់គាត់ឈ្មោះ [redacted] ភក្តី ហៅ សៀច ទៅដើរលេងនៅមុខកាក់ស់សាំងសូគីម៉ិច ពេលនោះឈ្មោះ [redacted] តុលា ហៅ តាំង ក៏មានជម្លោះជាមួយបុរសម្នាក់ទៀត ឃើញដូចនោះ ខ្លួន និងឈ្មោះ [redacted] ភក្តី ក៏ចូលទៅជួយវាយទៅជនរងគ្រោះតែពីរដៃប៉ុណ្ណោះ ភ្លាមនោះជនរងគ្រោះក៏រើខ្លួនរត់ចេញទៅ តែត្រូវឈ្មោះ ចៅ តុលា និងឈ្មោះ [redacted] ភក្តី ដេញតាមទាន់ និងវាយបន្ថែមទៀត ។

៥-តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភារម្យ បានឆ្លើយថា នៅថ្ងៃកើតហេតុ មិត្តភក្តិរបស់ខ្លួនបានទូរស័ព្ទប្រាប់ខ្លួនថា ប្អូនខ្លួនឈ្មោះ [redacted] ភារៈ ត្រូវគេសម្លាប់ ពេលមកកន្លែងកើតហេតុ ខ្លួនឃើញស្នាមរបួសលើខ្លួនប្អូនប្រុសខ្លួន គឺត្រូវជនល្មើសចាក់ត្រូវក្រោមដោះខាងឆ្វេង និងមួយកន្លែងទៀតត្រង់ឆ្អឹងជំនីខាងស្តាំ ។

៦-តាមចម្លើយសាក្សីឈ្មោះ [redacted] ភូ បានឆ្លើយថា នៅថ្ងៃកើតហេតុ វេលាម៉ោងប្រហែល ៧ និង ៣០ នាទី ខ្លួន និងមិត្តភក្តិខ្លួនពីរនាក់ទៀតឈ្មោះ [redacted] វ៉ាន់ថ និងឈ្មោះ [redacted] ភារៈ បានអង្គុយ លេងលើស្ទួនច្បារមុខកាក់ស់សាំងសូគីម៉ិច ពេលកំពុងអង្គុយនោះមានបុរសម្នាក់មកសួរ [redacted] ភារៈ ថាម៉េចបានជាមើលមុខវា ភ្លាមនោះក៏មានគ្នាវាពីរនាក់ទៀតចូលមកវាយលើឈ្មោះ [redacted] ភារៈ បណ្តាលឱ្យដួលទៅនឹងដី ឃើញដូចនោះខ្លួនមិនហ៊ានចូលជួយទេ ពេលខ្លួនរត់ចេញពីកន្លែងកើតហេតុបានប្រហែល ២០ម៉ែត្រ ខ្លួនបានឃើញជនល្មើសម្នាក់ មិនដឹងជាយកដែក ឬឈើទេចាក់ទៅលើជនរងគ្រោះ ហើយខ្លួនក៏បានរត់ទៅរោងចក្រទឹកកកហៅគេជួយ តែពេលត្រលប់មកវិញ ឈ្មោះ [redacted] ភារៈ បានស្លាប់បាត់ទៅហើយ ។

៧-តាមចម្លើយសាក្សីឈ្មោះ [redacted] ឆ្លើយថា នៅថ្ងៃកើតហេតុខ្លួន និងឈ្មោះ [redacted] រួមទាំងជនរងគ្រោះ បានអង្គុយលេងលើស្ពានច្បារមុខការ៉ាសសាំងសូគីម៉ិច ពេលកំពុងអង្គុយនោះ ជនសង្ស័យដើរចូលមកសម្លុតជនរងគ្រោះ ហើយបាននាំគ្នាព្រួតវាយលើជនរងគ្រោះ ឃើញដូចនោះខ្លួននិងមិត្តភក្តិមិនហ៊ានចូលជួយទេ ពេលវាយជនរងគ្រោះដួលទៅនឹងដី បក្សពួកជនសង្ស័យបានរត់គេចខ្លួនបាត់ ភ្លាមនោះខ្លួន និងមិត្តភក្តិ បានជួយលើកជនរងគ្រោះ ឃើញជនរងគ្រោះបានរបួសធ្ងន់ខ្លួនក៏ទៅហៅគ្នាទៅរកឡានដឹកកកមកជួយលើក តែពេលត្រឡប់មកវិញ ជនរងគ្រោះ បានស្លាប់ទៅហើយ ។

៨-តាមចម្លើយសាក្សីឈ្មោះ [redacted] បានឆ្លើយថា នៅថ្ងៃកើតហេតុ ខ្លួនបានទៅអង្គុយលេងនៅស្ពានច្បារមុខការ៉ាសសាំងសូគីម៉ិច ហើយក៏បានឃើញជនសង្ស័យ ៣នាក់ ព្រួតវាយទៅលើជនរងគ្រោះម្នាក់ ក្នុងចំណោមជនសង្ស័យទាំង ៣នាក់ ខ្លួនស្គាល់ ២នាក់ គឺឈ្មោះ [redacted] តុលា ហៅ តាំង និងឈ្មោះ គីង ត្រូវជាបងប្អូនជីដូនមួយនឹងគ្នា ចំណែកជនសង្ស័យម្នាក់ទៀតខ្លួនមិនស្គាល់ទេ ពេលវាយនោះខ្លួនឃើញឈ្មោះ [redacted] តុលា និងឈ្មោះ គីង បានដេញវាយជនរងគ្រោះរហូតដួលសន្លប់ទៅនឹងដី ទើបក្រុមជនល្មើសនាំគ្នាឈប់វាយ ហើយគេចខ្លួនបាត់ ។ ពេលនោះមិត្តភក្តិជនរងគ្រោះមកជួយលើកជនរងគ្រោះឲ្យអង្គុយលើកៅអីថ្ម ហើយខ្លួនក៏ទៅជួយដែរ ដោយបានឃើញជនរងគ្រោះរបួសធ្លុះដើមទ្រូង ប៉ុន្តែពុំឃើញមានឈាមហូរទេ លុះពេលខ្លួនជិះម៉ូតូទៅផ្ទះក៏បានជួបឈ្មោះ [redacted] តុលា និងឈ្មោះ គីង នៅក្នុងបន្ទាយព្រៃទំប ឫស្សីកែវ ពេលខ្លួនសួរនាំទើបឈ្មោះ [redacted] តុលា ប្រាប់ថាវាយកដែកកាំប៉ីធូចាក់លើជនរងគ្រោះ ហើយព្រមទាំងដកយកដែកកាំប៉ីធូនោះ មកបង្ហាញខ្លួនផងដែរ ។

៩-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ភក្តី ហៅ ស៊ៀប និងឈ្មោះ [redacted] សំណាង ហៅ គីង ដែលឆ្លើយថា ខ្លួនគ្រាន់តែវាយជនរងគ្រោះនឹងដៃ និងពុំមានចេតនាសម្លាប់ជនរងគ្រោះនោះទេ គ្រាន់តែជាចម្លើយដោះបន្ទុក ដើម្បីរួចផុតពីការទទួលខុសត្រូវចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្តតែប៉ុណ្ណោះ ។

១០-តាមចម្លើយរបស់ជនជាប់ចោទពីរនាក់ខាងលើ ចម្លើយរបស់ដើមបណ្តឹង និងចម្លើយរបស់សាក្សី មានលក្ខណៈស៊ីសង្វាក់ទៅនឹងរបាយការណ៍របស់សមត្ថកិច្ច និង ភស្តុតាងជាឯកសារផ្សេងៗទៀត ដែលអាចឲ្យតុលាការកំណត់បានថាជនជាប់ចោទទាំងបីខាងលើ ពិតជាបានធ្វើសកម្មភាពប្រព្រឹត្តបទល្មើស ឃាតកម្ម នៅចំណុចស្ពានច្បារមុខការ៉ាសសាំងសូគីម៉ិច ផ្លូវជាតិលេខ៥ ក្រុមទី៥ ភូមិឃ្លាំងសាំង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ពិតប្រាកដមែន ។



Scanned with CamScanner

១១-សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការទៅលើជនជាប់ចោទទាំងបីខាងលើ មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់អាចឲ្យតុលាការលើកយកមកពិចារណាបាន ។

១២-ជនជាប់ចោទទាំងបី គឺជាជនមានស្មារតីល្អ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចទទួលខុសត្រូវនូវអំពើដែលខ្លួនបានប្រព្រឹត្តតាមកំណត់ច្បាប់ ។

១៣-ជនជាប់ចោទឈ្មោះ [redacted] សំណាង ហៅ តឹង ទើបប្រព្រឹត្តបទល្មើសលើកទី១ ហើយជាអនីតិជន ដែលមានការយល់ដឹងទាបក្នុងអំពើដែលខ្លួនប្រព្រឹត្ត គប្បីតុលាការពិចារណាអំពីស្ថានសម្រាល ។

១៤-មានពិរុទ្ធភាព និងភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] តុលា ហៅ តាំង ,ឈ្មោះ [redacted] ភក្តី ហៅ សៀច និងឈ្មោះ [redacted] សំណាង ហៅ តឹង ពិតជាបានប្រព្រឹត្តនូវបទ ឃាតកម្ម ប្រព្រឹត្តនៅចំណុចសួនច្បារមុខការ៉ាសសាំងសូតីម៉ិច ផ្លូវជាតិលេខ៥ ក្រុមទី៥ ភូមិឃ្លាំងសាំង សង្កាត់ឬស្សីកែវ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

១៥-អំពើរបស់ជនជាប់ចោទទាំងបីនាក់ខាងលើបានបំពានទៅលើសិទ្ធិរបស់អ្នកដទៃ និងជាពិសេសធ្វើឲ្យប៉ះពាល់ដល់សន្តិសុខសង្គម និងសណ្តាប់ធ្នាប់សាធារណៈយ៉ាងធ្ងន់ធ្ងរ ។

១៦-ដើមបណ្តឹងរដ្ឋប្បវេណីបានចូលខ្លួនមកតុលាការដើម្បីតាំងខ្លួនជាដើមបណ្តឹង និងបានទាមទារសំណងជម្ងឺចិត្តចំនួន ៤០០០ (បួនពាន់)ដុល្លារអាមេរិក គប្បីតុលាការពិចារណានិងសម្រេចតាមច្បាប់ ។

**ហេតុដូច្នេះសម្រេច**

១-ផ្តន្ទាទោសៈ

ក-ឈ្មោះ [redacted] តុលា ហៅ តាំង ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ១១ (ដប់មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចាប់ឃុំខ្លួនបាន ។

ខ-ឈ្មោះ [redacted] ភក្តី ហៅ សៀច ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ១១ (ដប់មួយ)ឆ្នាំ ។

គ-ឈ្មោះ [redacted] សំណាង ហៅ តឹង ភេទប្រុស អាយុ ១៤ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៥ (ប្រាំ)ឆ្នាំ ។

ពីបទ ឃាតកម្ម ប្រព្រឹត្តនៅចំណុចសួនច្បារមុខការ៉ាសសាំងសូតី ម៉ិចផ្លូវជាតិលេខ៥ ក្រុមទី៥ ភូមិឃ្លាំងសាំង សង្កាត់ឬស្សីកែវ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១១ តាមបញ្ញត្តិមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។



Scanned with CamScanner

២-ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] គុណ ហៅ តាំង ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ យកមកទទួលទោសតាមអំណាចនៃសាលក្រមនេះ តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

៣-បង្គាប់ឱ្យជនជាប់ចោទទាំងបីសងសំណងរដ្ឋប្បវេណី ទៅឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ចំនួន ១៦ (ដប់ប្រាំមួយលាន) រៀល ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ភក្តី ហៅ សៀច ,ឈ្មោះ [redacted] សំណាង ហៅ គីង កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] គុណ ហៅ តាំង និងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ។

-បើកសិទ្ធិប្ដឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] |

[redacted]



Scanned with CamScanner